ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Dec-2022, 13:23
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Phillip RAPOZA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២២**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញា ស្តីពីផែនការនៃលក្ខខណ្ឌឃុំខ្លួន

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Fergal GAYNOR

**<u>ជនជាប់ចោទ</u>**
ខៀវ សំផន

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F77/1/1

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Falguni DEBNATH

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើរបស់ ខៀវ សំផន សុំឱ្យបង្គាប់សហព្រះរាជអាជ្ញាផ្ដល់ព័ត៌មានទាក់ទងទៅនឹងផែនការនៃលក្ខខណ្ឌឃុំខ្លួនរបស់គាត់នៅក្នុងពន្ធនាគារជាតិ ក្រោយពេលចេញសាលដីកាមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរក្នុងសំណុំរឿង ០០២/០២[1]។

## ១. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿងក្នុងសំណុំរឿង ០០២/០១ ដែលបានសម្រេចដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទឧក្រិដ្ឋមួយចំនួនក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅពេលនោះ និងភ្លាមៗក្រោយការផ្លាស់ទីប្រជាជនដោយបង្ខំពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានសម្រេចដាក់ទោសគាត់ជាប់ពន្ធនាគារអស់មួយជីវិត[2]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធ បានតម្កល់ និងបានសម្រេចដាក់ពិរុទ្ធភាពមួយចំនួន ហើយបានបង្គាប់ថា ខៀវ សំផន និង នួន ជា ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការផ្ទេរទៅអាជ្ញាធរជាតិ[3]។

2. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០២ ដែលបានដាក់ពិរុទ្ធភាព ខៀវ សំផន ពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ និងបានដាក់ទោស

---

[1] សំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្ដីពីផែនការនៃលក្ខខណ្ឌឃុំខ្លួន ខៀវ សំផន បន្ទាប់ពីការចេញសំអាងហេតុពេញលេញនៃសាលដីកាក្នុងការជំនុំជម្រះទីពីរនៃសំណុំរឿង ០០២ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២២ ឯកសារលេខ F77 ("សំណើសុំរបស់ ខៀវ សំផន (F77)")។

[2] សាលក្រមអង្គជំនុំជម្រះសាលាដំបូង សំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313 កថាខណ្ឌ ១១០៧ និងផ្នែកសម្រេចសេចក្ដី។

[3] សាលដីកាសំណុំរឿង ០០២/០១ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារលេខ F36 កថាខណ្ឌ ១១២១ និងផ្នែកសម្រេចសេចក្ដី។

គាត់ជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀត ប៉ុន្តែត្រូវបានស្រូបបញ្ចូលគ្នាទៅជាទោសជាប់ពន្ធនាគារអស់មួយជីវិតតែមួយដូចដែលបានដាក់ក្នុងសំណុំរឿង ០០២/០១[4]។

3. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាសង្ខេប ក្នុងសំណុំរឿង ០០២/០២ ដោយបានតម្កល់ការដាក់ពិរុទ្ធភាពភាគច្រើនលើ ខៀវ សំផន និងបានតម្កល់ការប្រកាសទោសអស់មួយជីវិតក្នុងសំណុំរឿង ០០២/០២ ដែលត្រូវអនុវត្តត្រួតគ្នាជាមួយនឹងទោសជាប់ពន្ធនាគារអស់មួយជីវិតដែលអង្គជំនុំជម្រះសាលាដំបូងបានប្រកាសក្នុងសំណុំរឿង ០០២/០១[5]។ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា "ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក. រង់ចាំការចេញសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរ និងការបញ្ចប់នៃការរៀបចំសម្រាប់ការផ្ទេរគាត់ដោយស្របតាមច្បាប់ទៅពន្ធនាគារដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់នោះ"[6]។

4. នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២២ ខៀវ សំផន បានដាក់សំណើនេះ("សំណើរបស់ ខៀវ សំផន ") សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់សហព្រះរាជអាជ្ញាផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងផែនការនៃលក្ខខណ្ឌឃុំខ្លួនរបស់គាត់ក្នុងពន្ធនាគារជាតិ ក្រោយពេលចេញសាលដីកាមានសំអាងពេញលេញក្នុងសំណុំរឿង ០០២/០២ ដើម្បីធានាថា លក្ខខណ្ឌនេះស្របតាមច្បាប់ជាធរមានចែងអំពីការការពារទណ្ឌិតដោយមនុស្សធម៌ និងការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះវ័យចាស់ជរា និងតម្រូវការថែទាំផ្នែកវេជ្ជសាស្ត្រ[7]។

5. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២២ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើនេះ ("សារណាតបរបស់សហព្រះរាជអាជ្ញា") ដោយបានផ្តល់ព័ត៌មានដែលទទួលបានមកទល់បច្ចុប្បន្នតាមរយៈអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ("អគ្គនាយកដ្ឋានពន្ធនាគារ") ទាក់ទងទៅនឹងលក្ខខណ្ឌឃុំខ្លួនរបស់ ខៀវ សំផន និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យបង្កើតនីតិវិធីផ្លូវការក្នុងការគ្រប់គ្រងការអនុវត្តន៍ទោសនេះ និងត្រួតពិនិត្យការប្រព្រឹត្តទៅលើពិរុទ្ធជនស្របតាមកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រម

---

[4] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465 ផ្នែកសម្រេចសេចក្តី ទំព័រ ២២៣១-២២៣២។

[5] សេចក្តីសង្ខេបសាលដីកាសំណុំរឿង ០០២/០២ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២២ ឯកសារលេខ F76.1 ("សេចក្តីសង្ខេបសាលដីកាសំណុំរឿង ០០២/០២ (F76.1)")។

[6] សេចក្តីសង្ខេបសាលដីកាសំណុំរឿង ០០២/០២ (F76.1) ផ្នែកសម្រេចសេចក្តី ទំព័រ ៣៤។

[7] *សូមមើល ឧ.* សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ២។

ព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀង")[8]។

## ២. សារណា

*សំណើរបស់ ខៀវ សំផន*

6. នៅក្នុងសំណើរបស់គាត់ ខៀវ សំផន បានសម្តែងការព្រួយបារម្ភអំពីលក្ខខណ្ឌនៃការឃុំឃាំងនៅពេលខាងមុខ និងបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់សហព្រះរាជអាជ្ញាផ្តល់ព័ត៌មានអំពីការរៀបចំដែលធ្វើឡើងសម្រាប់ការផ្ទេរគាត់ទៅពន្ធនាគារជាតិ និងលក្ខខណ្ឌដែលគាត់ត្រូវស្ថិតនៅក្នុងការបន្តអនុវត្តទោសរបស់គាត់ ដែលនេះជាផ្នែកនៃកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្រោមវិធាន ១១៣ នៃវិធានផ្ទៃក្នុង ដែលតម្រូវថា ត្រូវផ្តួចផ្តើម និងអនុវត្តការប្រកាសទោសនោះ[9]។ សំណើរបស់ ខៀវ សំផន ចង់ផ្តោតទៅលើវ័យចាស់ជរា និងលក្ខខណ្ឌសុខភាពទន់ខ្សោយរបស់គាត់ ដែលគាត់តម្រូវឱ្យមានការរៀបចំការឃុំឃាំងពិសេសដើម្បីឱ្យស្របតាមលិខិតុបករណ៍ជាតិ និងអន្តរជាតិដែលធានានូវការប្រព្រឹត្តទៅលើទណ្ឌិតដោយមនុស្សធម៌[10]។

7. ដើម្បីជួយសហព្រះរាជអាជ្ញាក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធ សំណើរបស់ ខៀវ សំផន បានរៀបរាប់សំណួរមួយចំនួនពាក់ព័ន្ធទៅនឹងថាតើ មន្ទីរឃុំឃាំង ការថែទាំផ្នែកវេជ្ជសាស្ត្រ ការបញ្ជូនទៅមន្ទីរពេទ្យមួយណាដែលត្រូវបានជ្រើសរើស និងថាតើ បន្ទប់ឃុំខ្លួនរបស់គាត់មានសម្ភារៈចាំបាច់សម្រាប់ការសម្រួលស្ថានភាពលំបាកក្នុងការផ្លាស់ទីរបស់គាត់ និងថាតើ ការរៀបចំនោះនឹងត្រូវធ្វើឡើងដើម្បីសម្រួលដល់ការចូលសួរសុខទុក្ខពីក្រុមគ្រួសារដើម្បីផ្តល់អាហារបន្ថែម និងជួយគាត់សម្រាប់ការចាំបាច់ផ្សេងៗ និងការជួយសម្រួល និងនីតិវិធីដែលមានអត្ថិភាពសម្រាប់គាត់ធ្វើការទំនាក់ទំនងជាមួយមេ

---

[8] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំព័ត៌មានទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួន ឯកសារលេខ F77/1 ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២២ យោងទៅលើកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធទៅនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំការផ្ទេរ និងការបំពេញកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ *ចូលជាធរមាន* នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២២ លេខ A/RES/75/257/B ("កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា")។

[9] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ២, ២៥។

[10] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ៥-១០, ១ -១៨, ២១។

ធាវីការពារក្តីរបស់គាត់ ដែរ ឬយ៉ាងណា[11]។ សំណើរបស់ ខៀវ សំផន បានលម្អិតផងដែរអំពីលក្ខខណ្ឌសុខភាពរបស់គាត់ដែលរួមមាន*ក្នុងចំណោមទោះ*បញ្ហាបេះដូង លើសឈាម និងទឹកនោមផ្អែមទើបកើតថ្មីៗ ដែលចាំបាច់ត្រូវទទួលបានការតាមដានផ្នែកវេជ្ជសាស្ត្រ[12]។ គាត់បានបន្ថែមថា បញ្ហាភ្នែក និងត្រចៀកមានសភាពដុនដាបធ្ងន់ធ្ងរក្នុងពេលថ្មីៗនេះ និងថា គាត់ត្រូវការជួយជាពិសេសសម្រាប់កិច្ចការប្រចាំថ្ងៃ[13]។ ទាក់ទងនឹងការផ្លាស់ទីរបស់គាត់ ខៀវ សំផន បានលើកឡើងថា គាត់ពុំអាចផ្លាស់ទីបានដោយគ្មានដែកច្រត់សម្រាប់ដើរ និងរទេះរុញ និងថា គាត់ត្រូវការ"បង្កាន់ដៃទប់"ដើម្បីកុំឱ្យដួលពេលទៅបន្ទប់ទឹក ឬបត់ជើង[14]។

8. ខៀវ សំផន បានលើកឡើងថា កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា បានរួមបញ្ចូលមុខនាទីនៃការគ្រប់គ្រងលើការអនុវត្តន៍ទោស និងការតាមដាននូវការប្រព្រឹត្តទៅលើទណ្ឌិត ប៉ុន្តែពុំបានបញ្ជាក់ជាក់លាក់ថាតើ មុខនាទីនេះជាក់ស្តែងត្រូវប្រតិបត្តិយ៉ាងដូចម្តេច រួមទាំងការដែល ខៀវ សំផន ត្រូវលើកបញ្ហាយន្តការនោះយ៉ាងដូចម្តេច នៅពេលដែលលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់កើតឡើងនោះ[15]។ សហមេធាវីការពារក្តី ខៀវ សំផន បានយល់ស្របបន្តធ្វើតំណាងឱ្យគាត់បន្ទាប់ពីការផ្ទេរគាត់ទៅពន្ធនាគារជាតិ និងបានសម្តែងក្តីបារម្ភពាក់ព័ន្ធនឹងកង្វះព័ត៌មានលើបញ្ហាថាតើ ពួកគេនឹងត្រូវរក្សាទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួន និងប្រើប្រាស់យន្តការនោះដូចម្តេច នៅពេលដែលបញ្ហាទាក់ទងទៅនឹងតម្រូវការសុខភាព និងលក្ខខណ្ឌនៃការឃុំខ្លួនកើតឡើង[16]។

*សារណាតបរបស់សហព្រះរាជអាជ្ញា*

9. សហព្រះរាជអាជ្ញាបានយល់ស្របជាមួយ ខៀវ សំផន ថា លក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់ ត្រូវ ស្របជាមួយនឹងច្បាប់ជាធរមាន និងត្រូវយកចិត្តទុកដាក់គ្រប់គ្រាន់លើវ័យចាស់ជរា និងសុខភាពទន់ខ្សោយ

---

[11] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ២២។

[12] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ១៧។

[13] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ១៧។

[14] សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ១៧។

[15] *សូមមើល* សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ១១-១៣។

[16] *សូមមើល* សំណើរបស់ ខៀវ សំផន (F77) កថាខណ្ឌ ១៤, ២៣។

របស់គាត់[17]។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាបានជំទាស់ថា ការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងលក្ខខណ្ឌនៃការឃុំខ្លួន ខៀវ សំផន ស្ថិតលើ អ.វ.ត.ក. ទាំងស្រុង ជាជាងលើសហព្រះរាជអាជ្ញា និងថា កាតព្វកិច្ចរបស់ អ.វ.ត.ក. ក្រោមកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា"ក្នុងការគ្រប់គ្រងការអនុវត្តន៍ទោស" និង"ការតាមដានការប្រព្រឹត្តទៅលើទណ្ឌិត"ពេញមួយអំឡុងពេលនៃដំណាក់កាលសម្រាប់កិច្ចការសេសសល់"អាចត្រូវបានអនុវត្តតាមរយៈនីតិវិធីផ្លូវការមួយ" ដូចជា តាមរយៈ"ការទំនាក់ទំនងជាមួយអង្គការឯករាជ្យ និងជឿជាក់បានដែលមានបទពិសោធន៍ក្នុងការតាមដានលក្ខខណ្ឌពន្ធនាគារ និងផ្តល់អនុសាសន៍ ឬតាមរយៈនីតិវិធីផ្លូវការដែលប្រើប្រាស់បុគ្គលិក ឬមន្ត្រីនៅ អ.វ.ត.ក."[18]។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល"ធ្វើការរៀបចំដើម្បីទទួលបានព័ត៌មានជាក់លាក់ចុងក្រោយ និងគួរជឿទុកចិត្តបានពាក់ព័ន្ធទៅនឹងទីតាំងនៃការឃុំឃាំង ការប្រែប្រួលដែលចាំបាច់ និងការវិវឌ្ឍន៍ក្នុងការអនុវត្តន៍នោះ និងគ្រឿងបរិក្ខារ និងការថែទាំផ្នែកវិជ្ជសាស្ត្រ"[19]។

10. ជាការឆ្លើយតបទៅនឹងព័ត៌មានដែលបានស្នើសុំក្នុងសំណើនោះ សហព្រះរាជអាជ្ញាបានលើកឡើងថា បើទោះបីជាខ្លួន"ពុំអាចផ្តល់ចម្លើយជាក់លាក់ក៏ដោយ [...] ក៏ពុំមានការជំទាស់ទៅនឹងការរួមចំណែកព័ត៌មានដែលខ្លួនមានទាក់ទងទៅនឹងផែនការសម្រាប់ការឃុំខ្លួន ខៀវ សំផន ជាអចិន្ត្រៃយ៍"ដែរ[20]។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាបានរាយការណ៍ថា បើទោះបីជាសហព្រះរាជអាជ្ញាបានជួប "ប្រជុំជាមួយមន្ត្រីនៃ[អគ្គនាយកដ្ឋាននៃពន្ធនាគារ]ដោយទទួលបានជោគជ័យ និងបានផ្តែផ្តា និងខិតខំប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់ ខៀវ សំផន នៅពេលខាងមុខក៏ដោយ ក៏ពុំមានព័ត៌មានណាមួយដែលខ្លួនបានទទួល គឺជាផ្នែកនៃនីតិវិធីផ្លូវការនៃការអនុវត្តន៍ដែលចងកាតព្វកិច្ចនោះឡើយ"[21]។

## ៣. ច្បាប់ជាធរមាន

11. វិធាន ១១៣ នៃវិធានផ្ទៃក្នុងចែងថា៖

---

[17] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ២។

[18] *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ២, ១១-១២។

[19] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ៩។

[20] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ២។

[21] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ៨។

(១) ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា [...]។

(២) សហព្រះរាជអាជ្ញាធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ [...]។

(៣) សហព្រះរាជអាជ្ញាអាចសុំជំនួយពីអាជ្ញាធរអនុវត្តច្បាប់ ដើម្បីធានាដល់ការអនុវត្តទោស។

12. កិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចែងថា "បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធីស្របតាមមាត្រា ១ នៃកិច្ចព្រមព្រៀង រួមទាំង បណ្តឹងសាទុក្ខនានាដែលពាក់ព័ន្ធនោះនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តអនុវត្តមុខនាទីខាងក្រោមសម្រាប់រយៈពេលបីឆ្នាំដំបូង" ដែលបានរួមបញ្ចូល"ការគ្រប់គ្រងការអនុវត្តន៍ទោសព្រមទាំងការតាមដានការប្រព្រឹត្តទៅលើទណ្ឌិត"[22]។

13. ច្បាប់កម្ពុជាឆ្នាំ ២០១១ ស្តីពីពន្ធនាគារចែងអំពី"គ្រប់គ្រងជនជាប់ឃុំឱ្យធានាបានសន្តិសុខ និងសុវត្ថិភាព សុខភាព និងមនុស្សធម៌ ស្របតាមគោលការណ៍អន្តរជាតិ និងវិធាននៃសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព"[23]។ មាត្រា ៣៨ កំណត់ថា៖

ជនជាប់ឃុំដែលមានជំងឺត្រូវទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ។ ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវឱ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ដែលតម្រូវឱ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុតតាមសំណើរបស់ជនជាប់ឃុំ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាល ត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ។ ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក។

---

[22] មាត្រា ២ នៃកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

[23] មាត្រា ២(ខ) នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១។

14. មាត្រា ១០(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជាក្នុងឆ្នាំ ១៩៩២ ចែងថា "បុគ្គលគ្រប់រូបដែលត្រូវបានដកហូតនូវសិទ្ធិសេរីភាពត្រូវទទួលបានការប្រព្រឹត្តដោយមនុស្សធម៌ និងការគោរពលើសេចក្តីថ្លៃថ្នូររបស់មនុស្ស"[24]។

15. វិធាននៃអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើទណ្ឌិតចែង*ក្នុងចំណោមនោះ*ថា៖

ទណ្ឌិតទាំងអស់ត្រូវទទួលបានការប្រព្រឹត្តទៅលើដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់ពួកគេជាមនុស្សជាតិ។ ទណ្ឌិតទាំងអស់ត្រូវទទួលបានការការពារពី និងពុំត្រូវទទួលរងការធ្វើទារុណកម្ម និងអំពើឃោរឃៅផ្សេងៗ ការធ្វើបាប ឬការបន្ទាបបន្ថោកសេចក្តីថ្លៃថ្នូរ ឬការដាក់ទណ្ឌកម្មដែលពុំអាចធ្វើយុត្តិកម្មបានទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ សុវត្ថិភាព និងសន្តិសុខរបស់ទណ្ឌិត បុគ្គលិក អ្នកផ្តល់សេវា និងអ្នកទៅសួរសុខទុក្ខ ត្រូវបានធានាគ្រប់ពេល។ [...]

ដើម្បីអនុវត្តគោលការណ៍ស្តីពីភាពមិនរើសអើង ពន្ធនាគារ និងរដ្ឋបាលត្រូវយកចិត្តទុកដាក់លើតម្រូវការរបស់ទណ្ឌិតម្នាក់ៗ ជាពិសេស ប្រភេទដែលងាយទទួលរងគ្រោះបំផុតនៅក្នុងពន្ធនាគារ។ វិធានការក្នុងការការពារ និងការលើកកម្ពស់សិទ្ធិរបស់ទណ្ឌិតដែលមានតម្រូវការពិសេស មានភាពចាំបាច់ និងពុំត្រូវបានចាត់ទុកថាជា ការរើសអើងឡើយ[25]។

## ៤. ការពិភាក្សា

16. ពុំមានភាគីណាមួយបានជំទាស់ថា ខៀវ សំផន ត្រូវអនុវត្តទោសក្នុងពន្ធនាគារជាតិដែលមានលក្ខខណ្ឌស្របតាមបទដ្ឋានអន្តរជាតិស្តីពីការប្រព្រឹត្តទៅលើទណ្ឌិត រួមទាំងបទប្បញ្ញត្តិស្តីពីសម្ភារៈជាក់លាក់ ឬការថែទាំវេជ្ជសាស្ត្រដោយផ្អែកលើវ័យចាស់ជរា និងសុខភាពទន់ខ្សោយ។ បន្ថែមលើនេះ ភាគីបានយល់ស្របថា រាជរដ្ឋាភិបាលកម្ពុជា គឺជារដ្ឋមួយដែលមានរបបអនុវត្តទោស និងមានកាតព្វកិច្ចក្រោមច្បាប់ជាតិ និងអន្តរជាតិក្នុងការផ្តល់លក្ខខណ្ឌនៃការឃុំឃាំងដែលស្របតាមបទដ្ឋានស្តីពីសិទ្ធិមនុស្សជា

[24] មាត្រា ១០(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយចូលជាធរមានថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ឯកសារលេខ 999 U.N.T.S. 171 និង 1057 U.N.T.S 407 ("ICCPR")។

[25] មហាសន្និបាតអង្គការសហប្រជាជាតិ, វិធាន ១ និង ២(២) វិធាននៃអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើទណ្ឌិត (វិធាន Nelson Mandela) ឯកសារលេខ U.N. Doc. A/RES/70.175 ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦។

មូលដ្ឋាន រួមទាំងកាតព្វកិច្ចខ្ពស់សម្រាប់ទណ្ឌិតដែលងាយទទួលរងគ្រោះដែលមានសុខភាពទន់ខ្សោយ លំបាកក្នុងការផ្លាស់ទី និងតម្រូវការទាក់ទងទៅនឹងវ័យចាស់ជរាដូចលក្ខខណ្ឌរបស់ ខៀវ សំផន ជាដើម[26]។

17. ខ្លឹមសារនៃការជំទាស់ក្នុងសំណើនេះគឺថាតើ នរណាជាអ្នកទទួលខុសត្រូវសម្រាប់ការអនុវត្តន៍ការប្រកាសទោសរបស់ ខៀវ សំផន ស្របតាមសិទ្ធិទទួលបានក្នុងមន្ទីរឃុំឃាំងក្នុងលក្ខណៈជាទណ្ឌិតដែលងាយទទួលរងគ្រោះ និងការត្រួតពិនិត្យបន្តបន្ទាប់លើការអនុវត្តន៍ រួមទាំងការតាមដានការឃុំខ្លួនគាត់ពេញមួយអំឡុងពេលនៃការជាប់ទោសអស់មួយជីវិត។ ភាគីបានគូសបង្ហាញផងដែរអំពីកង្វះភាពលម្អិតនៅក្នុងកិច្ចព្រមព្រៀងបន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការពន្យល់គ្រប់គ្រាន់ថាតើ យន្តការនោះនឹងត្រូវអនុវត្តមុខនាទីដែលនៅសេសសល់របស់ខ្លួនដែលបានលើកឡើងនោះយ៉ាងដូចម្តេច ក្នុងការ"គ្រប់គ្រងការអនុវត្តន៍ទោសព្រមទាំងការតាមដានការប្រព្រឹត្តទៅលើទណ្ឌិត" និងថាតើ ភាគីអាចស្នើសុំព័ត៌មានបន្ថែមស្តីពីបញ្ហានេះបានយ៉ាងដូចម្តេច។

*ការអនុវត្តន៍ទោសនៅ អ.វ.ត.ក.*

18. ការប្រកាសទោសនៅ អ.វ.ត.ក. ត្រូវបានអនុវត្តស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង ដែលតម្រូវថាសហព្រះរាជអាជ្ញា ដែលជាភាគីចោទប្រកាន់ ត្រូវផ្តួចផ្តើមគំនិតដោយខ្លួនឯង និងអនុវត្តការប្រកាសទោសដោយសហការជាមួយនឹងអាជ្ញាធរជាតិ[27]។ ពន្ធនាគារដែល ខៀវ សំផន នឹងត្រូវអនុវត្តទោសរបស់គាត់ នឹងត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋាននៃពន្ធនាគារ ហើយដោយសារជាផ្នែកនៃករណីយកិច្ចរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ចស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអាចសហការជាមួយមន្ត្រីនៃអគ្គនាយកដ្ឋាននៃពន្ធនាគារក្នុងការកំណត់អំពីមន្ទីរឃុំឃាំងសមស្របដែលអាចសម្រួលដល់តម្រូវការពិសេសរបស់ទណ្ឌិត។

19. គួររំឭកថា ចាប់តាំងពីខែ មេសា ដល់ខែ ឧសភា ឆ្នាំ ២០២២ សហព្រះរាជអាជ្ញាបានចាត់វិធានការចាប់ផ្តើមការអនុវត្តន៍ទោសជាប់ពន្ធនាគារអស់មួយជីវិតរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១

[26] *សូមមើលខាងលើ* ផ្នែកទី ៣ ("ច្បាប់ជាធរមាន" យោងទៅលើមាត្រា ៣៨ នៃច្បាប់កម្ពុជាស្តីពីទណ្ឌិតឆ្នាំ ២០១១ វិធាននៃអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើទណ្ឌិត និងមាត្រា ១០ នៃ ICCPR)។

[27] *សូមមើល* វិធាន ១១៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី ៩) ដែលត្រូវបានអនុម័តនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

តាមរយៈការស្នើសុំព័ត៌មានជាក់លាក់ និងឯកសារពីការិយាល័យរដ្ឋបាលក្នុងការជូនដំណឹងអំពីការពិភាក្សារបស់ខ្លួនជាមួយអាជ្ញាធរជាតិកម្ពុជា ដើម្បី"ធានានូវការផ្ទេរ ខៀវ សំផន ដោយប្រសិទ្ធភាព និងទាន់ពេលទៅពន្ធនាគារជាតិដែលមានលក្ខខណ្ឌនៃការឃុំឃាំងស្របជាមួយនឹងបទដ្ឋានអន្តរជាតិស្តីពីការប្រព្រឹត្តទៅលើទណ្ឌិត រួមទាំង បទប្បញ្ញត្តិស្តីពីសម្ភារៈពិសេស និងការសម្រួលផ្នែកវេជ្ជសាស្ត្រ"[28]។ នៅក្នុងការឆ្លើយឆ្លងតាមរយៈអនុស្សរណៈ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា ដោយផ្អែកលើសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០១ ដែលបានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត និងថា ដោយពុំគិតពីលទ្ធផលនៃសាលដីកាសំណុំរឿង ០០២/០២ ខៀវ សំផន នឹងត្រូវផ្ទេរទៅពន្ធនាគារជាតិដើម្បីអនុវត្តទោសរបស់គាត់ជាប់ពន្ធនាគារអស់មួយជីវិតក្រោយពេលចេញសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២[29]។ សហព្រះរាជអាជ្ញាបានស្នើសុំព័ត៌មាន និងឯកសារពីមន្ត្រីគ្រប់គ្រងមន្ទីរឃុំឃាំងនៅ អ.វ.ត.ក. តាមរយៈការិយាល័យរដ្ឋបាលដោយលើកសំណួរជាច្រើនផ្សេងៗគ្នាដូចជា *ក្នុងចំណោមនោះ*ពាក់ព័ន្ធទៅនឹងតម្រូវការពិសេសរបស់ ខៀវ សំផន វិធានការការពារជំងឺឆ្លងកូវីដ-១៩ ក្នុងការសម្រួលដល់ការចូលសួរសុខទុក្ខ សិទ្ធិទទួលបានការចូលសួរសុខទុក្ខ និងការរឹតត្បិតផ្នែកសុខភាពស្តីពីការចូលសួរសុខទុក្ខ អត្ថិភាពនៃបុគ្គលិកពេទ្យប្រចាំការពេញម៉ោង និងតួនាទី បទប្បញ្ញត្តិសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ និងបទដ្ឋានប្រតិបត្តិការ

---

[28] អនុស្សរណៈអន្តរការិយាល័យពីការិយាល័យសហព្រះរាជអាជ្ញាទៅការិយាល័យរដ្ឋបាល ចំណងជើងថា "ការអនុវត្តន៍ការប្រកាសទោសរបស់ ខៀវ សំផន" ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២២ ("អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាស្តីពីការអនុវត្តន៍ទោស") កថាខណ្ឌ ២។ *សូមមើលផងដែរ* អនុស្សរណៈអន្តរការិយាល័យពីការិយាល័យរដ្ឋបាលទៅប្រធានអង្គជំនុំជម្រះតុលាការកំពូលចំណងឃើញថា "អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាចំណងជើងថា 'ការអនុវត្តន៍របស់សហព្រះរាជអាជ្ញាលើការប្រកាសទោសរបស់ ខៀវ សំផន' ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២២" ថ្ងៃទី ២២ ខែ មេសា ២០២២ ("អនុស្សរណៈ OS ទៅប្រធានអង្គជំនុំជម្រះតុលាការកំពូល")។ អនុស្សរណៈអន្តរការិយាល័យពីប្រធានអង្គជំនុំជម្រះតុលាការកំពូលទៅការិយាល័យរដ្ឋបាលចំណងជើងថា "ការឆ្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យពីការិយាល័យរដ្ឋបាលពាក់ព័ន្ធទៅនឹងអនុស្សរណៈអន្តរការិយាល័យពីការិយាល័យសហព្រះរាជអាជ្ញាចំណងជើងថា 'ការអនុវត្តន៍របស់សហព្រះរាជអាជ្ញាលើការប្រកាសទោសរបស់ ខៀវ សំផន' ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២២" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២២ ("អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល")។ អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាទៅក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល ចំណងជើងថា "ការអនុវត្តន៍របស់សហព្រះរាជអាជ្ញាលើការប្រកាសទោសរបស់ ខៀវ សំផន" សំណើសុំឯកសារចម្លងនៃដែលបញ្ជាក់ត្រឹមត្រូវនូវផ្នែកនៃសាលក្រម និងសាលដីកាសំណុំរឿង ០០២/០១ ថ្ងៃទី ២០ ខែ ឧសភា ២០២២ ("អនុស្សរណៈរបស់សហព្រះរាជអាជ្ញាទៅក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល")។

[29] អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាស្តីពីការអនុវត្តន៍ទោស កថាខណ្ឌ ១។

នីតិវិធី ឬបទបញ្ញាដែលឆ្លើយតបផ្ទាល់ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា[30]។ សហព្រះរាជអាជ្ញាបានស្នើសុំផងដែរនូវព័ត៌មានជាក់លាក់ពីបុគ្គលិកពេទ្យប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក. ដូចជាថាតើការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រ ២៤ ម៉ោង និងបុគ្គលិកផ្នែកនេះចាំបាច់ ដែរ ឬយ៉ាងណា និងថាតើមានមន្ទីរពេទ្យជាក់លាក់ដែល ខៀវ សំផន គប្បីផ្ទេរទៅសម្រាប់សង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រប្រសិនបើចាំបាច់នោះ ដែរ ឬយ៉ាងណា[31]។

20. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឱ្យសហព្រះរាជអាជ្ញានូវឯកសារចម្លងដែលបានបញ្ជាក់ត្រឹមត្រូវនៃផ្នែកដែលពាក់ព័ន្ធនៃសាលក្រម និងសាលដីកាក្នុងសំណុំរឿង ០០២/០១ ក្នុងការសម្រួលដល់ដំណើរការនៃការត្រៀមរៀបចំការផ្ទេរដោយមានការសហការជាមួយនឹងអាជ្ញាធរជាតិ[32]។ ជាផលវិបាក សហព្រះរាជអាជ្ញាបានចាប់ផ្តើមធ្វើការជាមួយនឹងអាជ្ញាធរជាតិក្នុងការបញ្ចប់ការរៀបចំសម្រាប់ការផ្ទេរ ខៀវ សំផន នៅមុនការចេញសាលដីកាស្ថាពរក្នុងសំណុំរឿង ០០២/០២។

21. បើទោះបីទំនងជាថា សហព្រះរាជអាជ្ញាបានជួបជាមួយនឹងមន្ត្រីនៃអគ្គនាយកដ្ឋាននៃពន្ធនាគារ និងបានទទួលព័ត៌មានបឋមខ្លះពាក់ព័ន្ធទៅនឹងទីតាំងនៃពន្ធនាគារ និងលក្ខខណ្ឌ"អនាគត"ដែល ខៀវ សំផន នឹងត្រូវអនុវត្តទោសរបស់គាត់ក៏ដោយ ក៏សារណាតបរបស់សហព្រះរាជអាជ្ញាបង្ហាញថា ដំណើរការនៃការបញ្ចប់ការរៀបចំសម្រាប់ការផ្ទេរនេះ នៅពុំទាន់បានពេញលេញដោយសារពុំមានព័ត៌មាន "ចុងក្រោយ" ឬ"ជាក់លាក់" ដែលទទួលបានស្តីពីបញ្ហាសំខាន់ជាច្រើន[33]។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាពីមុនបានផ្តួចផ្តើមគំនិត និងបានអនុវត្តការប្រកាសទោសរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដោយជោគជ័យក្នុងសំណុំរឿង ០០១ ដោយបានសហការជាមួយនឹងអាជ្ញាធរជាតិ។

22. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្នុងសំណុំរឿង ០០១ បុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញាបានចុះទស្សនកិច្ចពន្ធនាគារខេត្តកណ្តាលពីរលើកក្នុងការពិនិត្យលើការសម្រួលដែលបានស្នើឡើងសម្រាប់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច នៅមុនធ្វើការសន្និដ្ឋានថា ការសម្រួលនោះបានការពារអត្ថប្រយោជន៍

---

[30] អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាស្តីពីការអនុវត្តន៍ទោស កថាខណ្ឌ ៣។

[31] អនុស្សរណៈអន្តរការិយាល័យរបស់សហព្រះរាជអាជ្ញាស្តីពីការអនុវត្តន៍ទោស កថាខណ្ឌ ៤។

[32] បញ្ជូនតាមរយៈអ៊ីម៉ែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២៣។

[33] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ៨។

របស់គាត់[34]។ បន្ទាប់មក សហព្រះរាជអាជ្ញាបានស្នើសុំជាផ្លូវការឱ្យផ្ទេរ កាំង ហ្គេចអ៊ាវ *ហៅ* ឌុច ទៅពន្ធនាគារខេត្តកណ្តាល ខណៈពេលស្នើសុំផងដែរនូវចំណាត់ការផ្លូវការពីអគ្គនាយកដ្ឋាននៃពន្ធនាគារ ថា ទីកន្លែង និងលក្ខខណ្ឌនៃការឃុំឃាំងមិនត្រូវប្រែប្រួលដែលធ្វើឱ្យប៉ះពាល់ដល់គាត់ក្នុងអំឡុងពេលនៃការជាប់ពន្ធនាគារអស់មួយជីវិតនោះឡើយ[35]។ សហព្រះរាជអាជ្ញាក៏បានសង្កេតផងដែរថា គណៈកម្មាធិការអន្តរជាតិសម្រាប់កាកបាទក្រហម ("ICRC") បានធ្វើការពិនិត្យពន្ធនាគារជាប្រចាំលើទណ្ឌិតទូទាំងប្រទេសកម្ពុជា រួមទាំងពន្ធនាគារខេត្តកណ្តាល[36]។

23. ទោះជាយ៉ាងណាក្តី ក្នុងរឿងក្តីបច្ចុប្បន្ន សហព្រះរាជអាជ្ញាមានបំណងបោះបង់ដោយពុំសមស្របនូវកាតព្វកិច្ចរបស់ខ្លួនតាមរយៈស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលដើរតួនាទីជំនួស និង"ធ្វើការរៀបចំដើម្បីទទួលបានព័ត៌មានជាក់លាក់ចុងក្រោយ និងជឿទុកចិត្តបានពាក់ព័ន្ធទៅនឹងទីតាំងនៃមន្ទីរឃុំឃាំង ការកែប្រែដែលចាំបាច់ និងការវិវឌ្ឍន៍ក្នុងការអនុវត្តន៍នោះ និងការជួយ និងការថែទាំផ្នែកវេជ្ជសាស្ត្រ"[37]។ ប្រសិនបើការរៀបចំដែលធានាលក្ខខណ្ឌនៃការឃុំឃាំងគ្រប់គ្រាន់សម្រាប់ ខៀវ សំផន នៅតែពុំទាន់រួចរាល់មកទល់ពេលចេញសាលដីកាមានសំអាងហេតុពេញលេញក្នុងសំណុំរឿង ០០២/០២ នោះ ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រហូតដល់មានការរៀបចំសមស្របត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា។

24. អង្គជំនុំជម្រះតុលាការកំពូលរំឭកសហព្រះរាជអាជ្ញាថា ក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះត្រឹមតែតម្កល់ការប្រកាសទោសប៉ុណ្ណោះ ពុំអាចអនុវត្តការប្រកាសនោះបានឡើយ។ ក្រោយពីបានធ្វើដូច្នេះនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២២ ក្នុងការប្រកាសសាលដីកាក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានចេញផ្នែកសម្រេចសេចក្តីដោយច្បាស់លាស់ និងបានបញ្ជាក់ថា នៅក្នុងការប្រកាសសេចក្តីសង្ខេបនៃសាលដីកាសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា "ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក. រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញ

---

[34] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការផ្ទេរ កាំង ហ្គេកអ៊ាវ ពីមន្ទីរឃុំឃាំង អ.វ.ត.ក. ទៅពន្ធនាគារជាតិ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ https://www.eccc.gov.kh/fr/node/26519 ("សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាខែ មិថុនា ឆ្នាំ ២០១៣")។

[35] សេចក្តី ប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាខែ មិថុនា ឆ្នាំ ២០១៣។

[36] សេចក្តី ប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាខែ មិថុនា ឆ្នាំ ២០១៣។

[37] សារណាតបរបស់សហព្រះរាជអាជ្ញា (F77/1) កថាខណ្ឌ ៩។

លេញជាលាយលក្ខណ៍អក្សរ និងការបញ្ចប់រួចរាល់នូវការរៀបចំសម្រាប់ការផ្ទេរដោយស្របតាមច្បាប់ទៅពន្ធនាគារដែលគាត់នឹងត្រូវអនុវត្តទោសបន្ត”[38]។

25. បន្ថែមលើនេះ តាមការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ព័ត៌មានដែលបានស្នើសុំដោយ ខៀវ សំផន រួមទាំងទីតាំងនៃការឃុំឃាំង ការជួយសម្រួលផ្នែកវេជ្ជសាស្ត្រ និងការកែប្រែបន្ទប់ឃុំខ្លួនរបស់គាត់ ដើម្បីជួយសម្រួលដល់ការផ្លាស់ទីរបស់គាត់ដែលចាំបាច់នោះ ជាការសមហេតុផល និងបានប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានលក្ខខណ្ឌនៃការឃុំឃាំងដោយមនុស្សធម៌ និងគ្រប់គ្រាន់។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា ដំណើរការនៃការសហការជាមួយអាជ្ញាធរជាតិក្នុងការបញ្ចប់រួចរាល់នូវការរៀបចំសម្រាប់ការផ្ទេរទៅពន្ធនាគារជាតិ ជាកាតព្វកិច្ចទាំងស្រុងរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង ក្នុងការអនុវត្តការប្រកាសទោសដោយសហការជាមួយអាជ្ញាធរជាតិ។

26. សហព្រះរាជអាជ្ញាពុំបានលម្អិតលើមូលហេតុដូចម្តេចបានជាពុំអាចទទួលបានចម្លើយជាក់លាក់ពីអាជ្ញាធរជាតិក្នុងអំឡុងពេលនៃកិច្ចប្រជុំ“ដោយជោគជ័យ និងបានផ្លែផ្កា” ជាពិសេសនៅពេលខ្លួនបានបំពេញតួនាទីជោគជ័យដូចគ្នាបន្ទាប់ពីការចេញសាលដីកាសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្គេក អ៊ាវ *ហៅ* ឌុច ដែលត្រូវបានផ្ទេរផងដែរទៅពន្ធនាគារតែមួយដូចគ្នាសម្រាប់ ខៀវ សំផន។ ប្រសិនបើសហព្រះរាជអាជ្ញាត្រូវការជួយបន្ថែមទៀតណាមួយក្នុងការសហការជាមួយអាជ្ញាធរជាតិ ដើម្បីបញ្ចប់ការរៀបចំសម្រាប់ការផ្ទេរ ខៀវ សំផន ការិយាល័យរដ្ឋបាលនឹងអាចជួយសម្រួលបាន។

*ការអនុវត្តន៍ការប្រកាសទោស និងការតាមដានលើទណ្ឌិតនៃ អ.វ.ត.ក.*

27. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាត្រូវបានបង្គាប់ឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យបានពេញលេញក្នុងការអនុវត្តន៍ការប្រកាសទោសរបស់ ខៀវ សំផន ដោយសហការជាមួយអាជ្ញាធរជាតិស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង។

28. ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែលជាផ្នែកមួយនៃមុខនាទីដែលនៅសេសសល់របស់ អ.វ.ត.ក. “អង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តអនុវត្ត” *ក្នុងចំណោមនោះ* ការត្រួតពិនិត្យលើការអនុវត្តន៍ការប្រកាស

---

[38] សេចក្តីសង្ខេបនៃសាលដីកាសំណុំរឿង ០០២/០២ (F76.1) ទំព័រ ៣៤ (សេចក្តីបញ្ជាក់បន្ថែម)។

ទោសព្រមទាំងការតាមដានការប្រព្រឹត្តទៅលើទណ្ឌិតសម្រាប់រយៈពេលបីឆ្នាំដំបូង[39]។ តាមការសង្កេតឃើញថា បើទោះបីជាកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ខ្វះព័ត៌មានជាក់លាក់លម្អិតថាតើ មុខនាទីនោះត្រូវអនុវត្តជាក់ស្តែងយ៉ាងដូចម្តេចក៏ដោយ ក៏មានការបញ្ជាក់ថា មុខនាទីទាំងនេះស្ថិតក្នុងវិសាលភាពនៃយន្តការកេរដំណែលរបស់ អ.វ.ត.ក.។ តាមការពិនិត្យធម្មតាលើទំព័រ ៥ នៃកិច្ចព្រមព្រៀងបន្ថែមបានបង្ហាញច្បាស់លាស់ថា គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីកំណត់អំពីមុខនាទីសេសសល់នៃយន្តការនោះ ដែលខុសពីការគូសបង្ហាញនូវក្របខ័ណ្ឌការងារលម្អិតទាក់ទងទៅនឹងការដែលមុខនាទីមួយៗ គប្បីបំពេញជាក់ស្តែងយ៉ាងដូចម្តេចនោះ។

29. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលស្នើថា ការិយាល័យរដ្ឋបាលផ្តល់ព័ត៌មានដែលទទួលបានមកអង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធទៅនឹងការអនុម័តក្របខ័ណ្ឌការងារដែលលម្អិតលើការដែលយន្តការកេរដំណែលត្រូវអនុវត្តមុខនាទីជាក់ស្តែងយ៉ាងដូចម្តេច ក្នុងការគ្រប់គ្រងការអនុវត្តន៍ការប្រកាសទោសដែលបានដាក់លើ ខៀវ សំផន ព្រមទាំងការតាមដានការប្រព្រឹត្តទៅលើគាត់ខណៈពេលអនុវត្តទោសទាំងនោះ។

[39] មាត្រា ២(១) នៃកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

## ៥. ផ្នែកសម្រេចសេចក្ដី

30. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**ទទួលយក**សំណើរបស់ ខៀវ សំផន និងបង្គាប់សហព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចពេញលេញស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង ក្នុងការផ្ដួចផ្ដើម និងអនុវត្តការប្រកាសទោស ដោយសហការជាមួយអាជ្ញាធរជាតិ រួមទាំងការបញ្ចប់រួចរាល់នូវការរៀបចំសម្រាប់ការផ្ទេរ ខៀវ សំផន ទៅពន្ធនាគារជាតិ។

**ស្នើ**ថា ការិយាល័យរដ្ឋបាលផ្ដល់ព័ត៌មានដែលទទួលបានមកអង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធទៅនឹងការអនុម័តក្របខ័ណ្ឌការងារដែលលម្អិតទៅលើការដែលយន្តការកេរដំណែល នឹងត្រូវអនុវត្តជាក់ស្ដែងនូវមុខនាទីសេសសល់យ៉ាងដូចម្ដេច ក្នុងការត្រួតពិនិត្យលើការអនុវត្តន៍ទោសត្រួតគ្នាដែលបានដាក់លើ ខៀវ សំផន ព្រមទាំងការតាមដានលើការប្រព្រឹត្តទៅលើគាត់ ខណៈពេលគាត់កំពុងអនុវត្តទោសទាំងនោះ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**